# ការវិភាគទិន្នន័យ ស្តីពីករណីវិវាទដីធ្លី នៅកម្ពុជា ក្នុងឆ្នាំ ២០០៩




មជ្ឈមណ្ឌលព័ត៌មានដីធ្លី

កម្មវិធីដីធ្លី និង ជីវភាព

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ~ ការវិភាគទិន្នន័យ**
**ស្តីពីករណីវិវាទដីធ្លី នៅកម្ពុជា ក្នុងឆ្នាំ២០០៩**


**បោះពុម្ពផ្សាយដោយៈ**
**មជ្ឈមណ្ឌលព័ត៌មានដីធ្លី**
**កម្មវិធីដីធ្លី និងជីវភាព**



**រចនាអត្ថបទដោយៈ**
**លោក ហុក ម៉េងហ៊ាន់ និង លោក ភួន យូ**

***វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា***

អាសយដ្ឋានៈ ផ្ទះលេខ ៩-១១ ផ្លូវ ៤៧៦ សង្កាត់ទួលទំពូង១ ប្រអប់សំបុត្រ ២២៩៥ ភ្នំពេញ -៣

ទូរស័ព្ទៈ (៨៥៥-២៣) ២១៤ ៤២៩

ទូរសារៈ (៨៥៥-២៣) ៩៩៤ ០៦៣

អ៊ីម៉េលៈ ngoforum@ngoforum.org.kh

គេហទំព័រៈ www.ngoforum.org.kh

# សេចក្តីថ្លែងអំណរគុណ

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះអស់លោក លោកស្រី និង បណ្តាអង្គការមួយចំនួន ដែលបានជួយក្រុមការងារមជ្ឈមណ្ឌលព័ត៌មានដីធ្លី ក្នុងការប្រមូល និងចងក្រងទិន្នន័យដែលបានរៀបរាប់នៅក្នុងរបាយការណ៍នេះ។ ក្រុមការងារមជ្ឈមណ្ឌលព័ត៌មានដីធ្លីសូមថ្លែងអំណរគុណដល់សមាគមការពារសិទ្ធិមនុស្សអាដហុក អង្គការលីកាដូ អង្គការវីជីឡែន អង្គការ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា អង្គការ ភូមិខ្ញុំ អង្គការ បីអេហ្វឌី អង្គការ ហ្គោដិក និង អង្គការអភិវឌ្ឍន៍ស្ត្រី ព្រមទាំងមន្ត្រីអាជ្ញាធរថ្នាក់ខេត្តទាំងអស់ ចំពោះការជួយជ្រោមជ្រែង និងគាំទ្រក្នុងការប្រមូលទិន្នន័យនេះ។ ក្រុមការងារមជ្ឈមណ្ឌលព័ត៌មានដីធ្លី ក៏សូមថ្លែងអំណរគុណផងដែរចំពោះ អង្គការអុកហ្វាមអង់គ្លេស ដែលបានផ្តល់អោយនូវទិន្នន័យដែលមានស្រាប់អំពីករណីវិវាទដីធ្លី និងឯកសារពាក់ពន្ធ័មួយចំនួន ។ ជាចុងក្រោយ មជ្ឈមណ្ឌលព័ត៌មានដីធ្លីសូមថ្លែងអំណរគុណចំពោះបណ្តាអង្គការ និង តំណាងសហគមន៍ទាំងអស់ដែលបានចំណាយពេលវេលា និងបានផ្តល់នូវព័ត៌មាន ខណៈពេលដែលក្រុមការងារមជ្ឈមណ្ឌលព័ត៌មានដីធ្លី ចុះទៅផ្ទៀងផ្ទាត់ពត៌មាននៅតាមបណ្តាខេត្ត និងតាមសហគមន៍នានា ។

© វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា — ២០១០

# ការវិភាគទិន្នន័យ ស្ដីពីករណីវិវាទដីធ្លី នៅកម្ពុជា ក្នុងឆ្នាំ២០០៩

| *មាតិកា* | *ទំព័រ* |
|---|---|


*សេចក្ដីផ្ដើម*......................................................................................*១*

*វិធីសាស្ត្រនៃការប្រមូលទិន្នន័យ*....................................................*៣*

*លទ្ធផលនៃការវិភាគទិន្នន័យ*..........................................................*៥*

- ការកើតឡើងករណីវិវាទដីធ្លី ..................................................*៥*
- បញ្ហានៃដីទំនាស់ ..................................................................*៦*
- ដំណើរការនៃការដោះស្រាយវិវាទ ...........................................*១១*

*សេចក្ដីសន្និដ្ឋាន*...........................................................................*១៥*

*ទិន្នន័យករណីវិវាទដីធ្លីបញ្ជាក់តាមផែនទី*............................................*១៧*

ឧបសម្ព័ន្ធ ១:

ចំនួនករណីវិវាទដីធ្លីតាមបណ្ដាខេត្ត..........................................................*១៧*

ឧបសម្ព័ន្ធ ២:

ផែនទីបញ្ជាក់អំពីចំនួនគ្រួសាររងផលប៉ះពាល់តាមបណ្ដាខេត្ត.....................*១៨*

# ការវិភាគទិន្នន័យ ស្តីពីករណីវិវាទដីធ្លី នៅកម្ពុជា ក្នុងឆ្នាំ២០០៩

## សេចក្តីផ្តើម

មជ្ឈមណ្ឌលព័ត៌មានដីធ្លី គឺជាគំរោងមួយនៅក្នុងកម្មវិធីដីធ្លី និងជីវភាពរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ។ មជ្ឈមណ្ឌលនេះត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៦ ក្នុងគោលបំណងដើម្បីប្រមូលព័ត៌មានដែលទាក់ទងទៅនឹងបញ្ហាដីធ្លី និងធនធានធម្មជាតិ និងចងក្រងទុកជាឯកសារនូវ ករណីដីធ្លី និងព្រៃឈើ ។ មជ្ឈមណ្ឌលព័ត៌មានដីធ្លី ត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងកង្វះខាតទិន្នន័យ និងព័ត៌មានផ្សេងៗ ដែលត្រូវបានប្រមូល អំពីបញ្ហាដីធ្លី និងដំណើរការនៃការដោះស្រាយករណីទាំងនោះ ដើម្បីអោយបានយល់អំពីប្រភេទនៃបញ្ហា និងរក្សាទុកជាមូលដ្ឋាន សំរាប់ធ្វើការតស៊ូមតិ និងការពិភាក្សាគោលនយោបាយផ្សេងៗប្រកបដោយប្រសិទ្ធិភាព។

របាយការណ៍វិភាគទិន្នន័យករណីវិវាទដីធ្លីប្រចាំឆ្នាំនេះ មានសារៈសំខាន់យ៉ាងសំខាន់ក្នុងការតស៊ូមតិដើម្បីឱ្យមានការផ្លាស់ប្តូរគោលនយោបាយទាក់ទងទៅនឹងដំណើរការនៃការដោះស្រាយករណីវិវាទដីធ្លី ។ របាយការណ៍នេះ គឺជារបាយការណ៍វិភាគទិន្នន័យករណីវិវាទដីធ្លីលើកទី៣ ហើយដែលត្រូវបានរៀបចំឡើងដោយមជ្ឈមណ្ឌល

ព័ត៌មានដីធ្លី  បន្ទាប់ពីបានទទួលទិន្នន័យដើមពីអង្គការអុកហ្វាមអង់គ្លេសនៅឆ្នាំ២០០៦ ។ ករណីវិវាទដីធ្លី ត្រូវបានដឹងឮជាទូទៅថាជាបញ្ហាក្តៅកើតនៅក្នុងប្រទេសកម្ពុជា នៅក្នុង២-៣ទសវត្សចុងក្រោយនេះ ។ នៅក្នុងករណីវិវាទជាច្រើនយើងបានរកឃើញថាជាប្រភេទវិវាទដែលទាក់ទងទៅនឹងការបាត់បង់នូវលទ្ធភាពក្នុងការទទួលបាននូវធនធានជាលក្ខណៈប្រពៃណី និងគំលាតយ៉ាងធំអំពីបែបបទនៃការគ្រប់គ្រងជាលក្ខណៈប្រពៃណី និងការគ្រប់គ្រងដោយអំណាចនីតិបញ្ញត្តិ ។ ធនាគារពិភពលោកបានធ្វើការកត់សំគាល់នៅក្នុងឆ្នាំ២០០៣ ថាការបរាជ័យក្នុងការអនុវត្តនីច្បាប់នានាទាក់ទងទៅនឹងដីធ្លី និងធនធានធម្មជាតិដោយសារតែការអនុវត្តន៏ជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានចំពោះជីវភាពរបស់ពួកគាត់ដែលជាហេតុនាំអោយវិវាទកើតមានឡើង ។

ករណីវិវាទដីធ្លីបានធ្វើអោយមានការចាប់អារម្មណ៏យ៉ាងខ្លាំងពីសំណាក់មហាជនរួមទាំងអាជ្ញាធររាជរដ្ឋាភិបាល ម្ចាស់ជំនួយ ដៃគូអភិវឌ្ឍន៏ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលទាំងមូលទៀតផង ។ ដោយមើលឃើញនូវបញ្ហាអស់ទាំងនេះស្ថាបន័មានសមត្ថកិច្ចផ្សេងៗបានបង្កើតឡើងនូវវិធានការ និងយុទ្ធសាស្រ្តជាច្រើន ហើយបានដាក់អោយអនុវត្ត ។ ទោះជាយ៉ាងនេះក្តី លទ្ធផលដំណើរការនៃការដោះស្រាយវិវាទដីធ្លី ត្រូវបានគេរាយការណ៏ផ្សេងៗគ្នាក្នុងចំណោមអ្នកពាក់ព័ន្ធទាំងនោះ ។ ដូច្នេះហើយ របាយការណ៏នៃការវិភាគទិន្នន័យករណីវិវាទដីធ្លីនេះ គឺដើម្បីបង្ហាញអោយឃើញអំពីប្រភេទនៃវិវាទដីធ្លី នៅប្រទេសកម្ពុជាក្នុងពេលកន្លងទៅ និងដាក់ជូននូវភស្តុតាងទៅអ្នកពាក់ព័ន្ធទាំងនោះ ។ លទ្ធផលនៃការវិភាគនេះ

រំពឹងថានឹងអាចផ្ដល់នូវអនុសាសន៍អនុវត្តជាក់ស្ដែងក្នុងការចូលរួមក្នុងដំណើរការនៃដោះស្រាយវិវាទដីធ្លីអោយកាន់តែមានភាពប្រសើរឡើងនាពេលអនាគត ។

គោលបំណងសំខាន់ៗនៃរបាយការណ៍វិភាគទិន្នន័យប្រចាំឆ្នាំនេះ គឺ (ក) ដើម្បីបង្ហាញអំពីស្ថានភាពនៃករណីវិវាទដីធ្លី និងទិដ្ឋភាពទូទៅនៃដំណើរការនៃការដោះស្រាយវិវាទក្នុងឆ្នាំ២០០៩ និង (ខ) ដើម្បីបង្ហាញសាធារណៈជនអំពីដំណើរការនៃការដោះស្រាយព្រមទាំងកត្តាមួយចំនួនដែលនាំទៅរកដំណោះស្រាយនៃវិវាទដីធ្លីទាំងនោះ ។

## *វិធីសាស្ត្រនៃការប្រមូលទិន្នន័យ*

មជ្ឈមណ្ឌលព័ត៌មានដីធ្លី ធ្វើការចងក្រងទិន្នន័យ តែប្រភេទករណីវិវាទដីធ្លីដែលមានចំនួនគ្រួសាររងផលប៉ះពាល់លើសពី៥គ្រួសារឡើងទៅ ។ ទិន្នន័យដើមដែលបានចងក្រង និងរក្សាទុកនៅក្នុងប្រពន្ធ័ទិន្នន័យរបស់មជ្ឈមណ្ឌលព័ត៌មានដីធ្លីគឺមានប្រហែល ២000ករណី ។ នៅដើមឆ្នាំ ២០០៩ យើងបានធ្វើការផ្ទៀងផ្ទាត់ទិន្នន័យឡើងវិញ ហើយបានរកឃើញថាមានករណីចំនួន ៨១២ករណី ឆ្លើយតបទៅនឹងលក្ខខណ្ឌកំណត់ ព្រមទាំងបានធ្វើបច្ចុប្បន្នភាពករណីសំរាប់ប្រព័ន្ធទិន្នន័យរបស់យើង ។ ស្ថានភាពករណីវិវាទនីមួយៗត្រូវបានតាមដាមយ៉ាងទៀងទាត់តាមមធ្យោបាយផ្សេងៗ ជាពិសេសធ្វើការសហការជាមួយអង្គការសមាជិកបណ្ដាញ និងធ្វើការតាមដានករណីជាមួយភ្នាក់ងារប្រពន្ធ័ផ្សព្វផ្សាយក្នុងស្រុក ដូចជា វិទ្យុអាស៊ីសេរី កាសែតកោះសន្តិភាព រស្មីកម្ពុជា ឌឺឃែមបូឌាដេលី និង កាសែតភ្នំពេញប៉ុស្តិ៍ ។ វិធីសាស្ត្រតាមដានស្ថានភាពករណីមួយទៀតគឺតាមរយៈអង្គការ

សមាជិកបណ្តាញដីធ្លីដែលមានការិយាល័យនៅតាមខេត្តនីមួយៗក្នុងអំឡុងពេលកិច្ចប្រជុំប្រចាំខែ បណ្តាញដីធ្លីដើម្បីអភិវឌ្ឍន៍របស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា។

លើសពីនេះទៅទៀត នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ យើងបានរៀបចំសិក្ខាសាលាថ្នាក់ជាតិមួយនៅភោជនីយដ្ឋានប៉ៃតង ក្រុងភ្នំពេញ ជាមួយអង្គការសមាជិកបណ្តាញដែលមានការិយាល័យនៅតាមបណ្តាខេត្តនានាដើម្បី ធ្វើបច្ចុប្បន្នភាពលើករណីទាំងនោះ។ គោលបំណងចំបងនៃការរៀបចំសិក្ខាសាលានេះ គឺដើម្បីផ្តល់ឱកាសអោយអង្គការសមាជិកបណ្តាញដែលធ្វើការលើបញ្ហាដីធ្លីបានពិភាក្សាលើបញ្ហាដីធ្លី និងផ្តល់នូវអនុសាសន៍លើទម្រង់ទិន្នន័យដែលពួកគាត់បានប្រើប្រាស់សំរាប់ធ្វើបច្ចុប្បន្នភាពករណី និងដំណើរការនៃការដោះស្រាយករណីវិវាទដីធ្លីនៅក្នុងខេត្តរបស់ពួកគាត់។

យើងបានធ្វើការតាមដាន និងធ្វើបច្ចុប្បន្នភាពករណីក្នុងចំណោមករណីវិវាទដីធ្លីទាំង៨១២ករណី រួមទាំងករណីវិវាទដែលបានកើតឡើងក្នុងឆ្នាំ២០០៩ផងរកឃើញថាមានករណីចំនួន២៣៦ករណីនៅមិនទាន់ត្រូវបានដោះស្រាយនៅឡើយឬបានដោះស្រាយតែផ្នែកខ្លះប៉ុណ្ណោះ ហើយទិន្នន័យនេះសំរាប់ធ្វើការវិភាគក្នុងឆ្នាំ២០០៩នេះ។ ករណីវិវាទដីធ្លីដែលបានដោះស្រាយទាំងស្រុងរួចហើយមុនឆ្នាំ២០០៩មិនត្រូវបានរាប់បញ្ចូលក្នុងចំនួនករណីទាំង២៣៦នេះទេ។ គ្រប់ករណីវិវាទដីធ្លីដែលបានធ្វើបច្ចុប្បន្នភាពនេះ គឺធ្វើនៅក្នុងអំឡុងខែកក្កដា រហូតដល់ខែធ្នូ ឆ្នាំ២០០៩ ដោយបានចុះទៅដល់ទីកន្លែងកើតហេតុតែម្តង។ គ្រប់ទិន្នន័យទាំងអស់ត្រូវបាន

ផ្ទៀងផ្ទាត់ឡើងវិញ និងបានរក្សាទុកនៅក្នុងប្រព័ន្ធទិន្នន័យរបស់មជ្ឈមណ្ឌលព័ត៌មានដីធ្លីបែបជាប្រពន្ធ័ព័ត៌មានភូមិសាស្ត្រ (GIS) ហើយទិន្នន័យទាំងនេះត្រូវបានធ្វើការវិភាគដោយបានធ្វើការប្រមូលចងក្រងដោយបានប្រើប្រាស់ឧបករណ៍វិភាគផ្សេងៗ រួមទាំង SPSS, MS Excel និង ការវិភាគទិន្នន័យប្រព័ន្ធព័ត៌មានទីតាំងភូមិសាស្ត្រ (GIS) ដើម្បីជួយផ្តល់នូវរូបភាពទូទៅនៃវិវាទដីធ្លី បែបជាទិន្នន័យស្ថិតិ និងទីតាំងភូមិសាស្ត្រ នៅកម្ពុជា ។

## លទ្ធផលនៃការវិភាគទិន្នន័យ:

លទ្ធផលនៃការវិភាគខាងក្រោម គឺការវិភាគករណីវិវាទដីធ្លីចំនួន២៣៦ ករណីដែលត្រូវបានរកឃើញថាមិនទាន់ត្រូវបានដោះស្រាយ ឬបានដោះស្រាយតែផ្នែកខ្លះនៅក្នុងប្រព័ន្ធទិន្នន័យរបស់មជ្ឈមណ្ឌលព័ត៌មានដីធ្លី ។ លទ្ធផលនៃការវិភាគទិន្នន័យ ។មានដូចខាងក្រោម:

## ការកើតឡើងករណីវិវាទដីធ្លី

ចំនួនករណីវិវាទដីធ្លីដែលកើតឡើងថ្មីនៅក្នុងឆ្នាំ២០០៩នេះ គឺមានត្រឹមតែ ០៩ ករណីប៉ុណ្ណោះ ដោយរាប់បញ្ចូលទាំងករណីវិវាទដែលដោះស្រាយរួចនិងករណីមិនទាន់ដោះស្រាយ ។ យោងតាម

តួលេខ ១.១: និន្នាការនៃវិវាទដីធី



តួលេខនេះករណីវិវាទដីធ្លីបានធ្លាក់ចុះ បើប្រៀបធៀបទៅនឹងចំនួនករណីវិវាទដីធ្លីនៅក្នុងឆ្នាំ២០០៨។ ដូច្នេះទិន្នន័យថ្មីនេះត្រូវបានរាប់បញ្ចូលទាំងករណីវិវាទដីធ្លីទាំង ០៩ និងករណីវិវាទចំនួន២២៧ករណីទៀតដែលនៅសល់ហើយមិនទាន់ត្រូវបានដោះស្រាយ ឬដោះស្រាយបានផ្នែកខ្លះតាំងពីឆ្នាំ២០០៨ ឬអាចនៅសល់មុនឆ្នាំ២០០៨ ទៅទៀត។ ក្នុងចំណោមករណីវិវាទទាំង២៣៦ករណីនេះ គឺមានជិត៥០% នៃករណីវិវាទបានកើតឡើងនៅក្នុងឆ្នាំ២០០៨ ហើយ២៥%ទៀតបានកើតឡើងតាំងពីឆ្នាំ១៩៩៩ និងមុននេះទៅទៀត។ (*សូមមើលតួលេខ ១.១* )។ បើទោះបីជាចំនួនសរុបនៃករណីវិវាទដីធ្លីបានធ្លាក់ចុះនៅក្នុងឆ្នាំ២០០៩ ប៉ុន្តែទីតាំងកើតហេតុនៃករណីវិវាទដីធ្លីទាំងនេះមិនខុសគ្នាទេរវាងឆ្នាំ២០០៩ និងឆ្នាំ២០០៨ដោយភាគច្រើនករណីវិវាទបានកើតឡើងនៅក្នុងតំបន់ដែលមានកំណើនសេដ្ឋកិច្ចខ្ពស់រួមមានខេត្តបាត់ដំបង ខេត្តព្រះសីហនុ ខេត្តបន្ទាយមានជ័យ និងខេត្តកណ្តាល (*សូមមើលទិន្នន័យករណីវិវាទតាមខេត្ត-ក្រុង នីមួយៗ ដែលមានភ្ជាប់នៅឧបសម្ព័ន្ធ ១*)។

## *បញ្ហានៃដីទំនាស់*

នៅក្នុងចំណោមករណីវិវាទដីធ្លីទាំង២៣៦ករណីនោះ មានដីប្រហែល៦០% គឺជាប្រភេទដីកសិកម្មដែលមានទាំងដីចំការ និងដីស្រែ។ បើគិតជាមធ្យមភាគផ្ទៃដីទំនាស់មានដល់ទៅ២០១ ហិកតា បើគិតពីអត្រាទាបបំផុត០.០៣ ហិកតា និងអាត្រាខ្ពស់បំផុត២៥០០ ហិកតា។ ករណីវិវាទដីធ្លីដែលមានទំហំដីតូចៗនោះ គឺច្រើនទាក់ទងទៅនឹងប្រភេទដីសាធារណៈ ដូចជា ដីផ្លូវសហគមន៍ ឬដីវត្តអារាម

ផ្សេងៗ ហើយករណីវិវាទដីធ្លីដែលមានទំហំធំៗនោះគឺទាក់ទងទៅនឹងវិវាទរវាងសហគមន៍ដែលពឹងអាស្រ័យព្រៃឈើ និងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចដែលបានផ្តល់អោយដោយរាជរដ្ឋាភិបាល ។

*តួលេខ ១.២: ភាគរយនៃចំនួនគ្រួសារពាក់ព័ន្ធករណីវិវាទនីមួយៗ*




គិតជាមធ្យមភាគក្នុងករណីវិវាទមួយមានចំនួនគ្រួសារដែលរងផលប៉ះពាល់រហូតដល់១២៥គ្រួសារ ហើយចំនួនគ្រួសារដែលរងផលបះពាល់ច្រើនបំផុតមានរហូតដល់៨៦០គ្រួសារក្នុងមួយករណី។ ទោះជាយ៉ាងនេះក្តី ចំនួនករណីវិវាទដីធ្លីតិចជាងពាក់កណ្តាល គឺ (៤១%) មានចំនួនគ្រួសារដែលរងផលប៉ះពាល់តិចជាង៥០គ្រួសារ ហើយចំនួនករណីវិវាទដីធ្លីមួយភាគប្រាំស្មើនឹង (២០%) ដែលមានគ្រួសាររងផលប៉ះពាល់ច្រើនជាង២០០គ្រួសារ (*សូមមើល តួលេខ១.២* )។ តាមការវិភាគក៏បានបង្ហាញអោយឃើញផងដែរថា ខេត្តបាត់ដំបង និង ខេត្តព្រះសីហនុគឺជាខេត្តដែលមាន

អត្រាខ្ពស់ជាងគេក្នុងចំណោមបណ្តាខេត្តទាំង៥ដែលមានករណីវិវាទដីធ្លីកើតឡើងច្រើនជាងគេ។ តែទោះបីជាយ៉ាងនេះក្តី ភាគច្រើននៃករណីវិវាទទាំងនោះ មានចំនួនគ្រួសារដែលរងផលប៉ះពាល់តិចជាង៥០គ្រួសារ ។ ផ្ទុយទៅវិញ ចំពោះបណ្តាខេត្តដែលមានអាត្រាខ្ពស់ជាងគេ ០៣ផ្សេងទៀត គឺខេត្តបន្ទាយមានជ័យ ខេត្តកណ្តាល និងនៅទីក្រុងភ្នំពេញដែលមានមធ្យមភាគនៃចំនួនគ្រួសាររងផលប៉ះពាល់ខ្ពស់ជាងគេ។ *ព័ត៌មានលំអិតអំពីចំនួនគ្រួសារដែលរងផលប៉ះពាល់ សូមមើលឧបសម្ព័ន្ធ ២ស្តីពី*)។

តារាងខាងក្រោមនឹងបញ្ជាក់អំពីប្រភេទដីទំនាស់ផ្សេងៗគ្នា និងភាពជាប់ទំនាក់ទំនងគ្នាទៅនឹងលទ្ធផលដំណើរការនៃការដោះស្រាយករណីវិវាទទាំងនោះ។ បើទោះបីជាភាគច្រើនបំផុតនៃដីទំនាស់បានបញ្ជាក់ថា ជាប្រភេទដីកសិកម្មក៏ដោយ ប៉ុន្តែលទ្ធផលនៃការដោះស្រាយបានបង្ហាញថាប្រភេទដីលំនៅដ្ឋានច្រើនក៏កំពុងស្ថិតនៅក្នុងដំណើរការដោះស្រាយផងដែរ (១០ករណីក្នុងចំណោម៤៨ករណីត្រូវបានដោះស្រាយ)។ ប្រភេទដីកសិកម្មអាចចាត់ទុកបានថាមានចំណាត់ថ្នាក់លេខពីរដែលត្រូវបានដោះស្រាយរួច។ នៅក្នុងតារាងខាងក្រោមនេះ ក៏បានបញ្ជាក់គួរអោយចាប់អារម្មណ៍ផងដែរអំពីករណីវិវាទដីធ្លីជាច្រើនមិនទាន់ត្រូវបានដោះស្រាយនៅឡើយដែលប្រភេទដីកសិកម្ម (មានចំនួន៩៤ករណី ក្នុងចំណោម១៦០ករណី)។ តាមការវិភាគបង្ហាញថា ប្រសិនបើករណីវិវាទដីកសិកម្មនៅតែមិនត្រូវបានដោះស្រាយទេនោះនឹងមានហានិភ័យ កើតឡើងចំពោះជីវភាពរបស់សហគមន៍និងសុវត្ថិភាពសន្តិសុខស្បៀងអាហារ។

### តារាង ១.១: ប្រភេទដីវិវាទ និង ស្ថានភាពដំណោះស្រាយ

| ប្រភេទដី | ស្ថានភាពដំណោះស្រាយ | | | | | |
|---|---|---|---|---|---|---|
| | ដំណើរការដោះស្រាយ | មិនទាន់ដោះស្រាយ | បោះបង់បណ្តឹង | គ្មានព័ត៌មានអំពីដំណោះស្រាយ | គ្មានទិន្នន័យគ្រប់គ្រាន់ | សរុបប្រភេទដី |
| ដីកសិកម្ម | ២៥ | ៩៤ | ៤ | ១០ | ៨ | ១៤១ |
| ដី ព្រៃ | ៣ | ១៦ | ០ | ៣ | ០ | ២២ |
| ដីលំនៅដ្ឋាន | ១០ | ៣១ | ១ | ២ | ៤ | ៤៨ |
| ផ្សេងៗ | ១ | ៧ | ២ | ០ | ១ | ១១ |
| គ្មានទិន្នន័យ | ២ | ១២ | ០ | ០ | ០ | ១៤ |
| **សរុប ករណី** | **៤១** | **១៦០** | **៧** | **១៥** | **១៣** | **២៣៦** |
| ***ភាគរយ*** | ***១៧.៣៧%*** | ***៦៧.៨០%*** | ***២.៩៧%*** | ***៦.៣៦%*** | ***៥.៥១%*** | ***១០០%*** |

ក្នុងចំណោមករណីវិវាទដីធ្លីចំនួន២៣៦ករណីនេះ គឺមានតែ១៧%ប៉ុណ្ណោះដែលមានដំណើរការដោះស្រាយហើយមានលទ្ធផលខ្លះៗ ហើយនៅមានករណីចំនួន៦៧%ករណីទៀតមិនទាន់ត្រូវបានដោះស្រាយនៅឡើយនៅក្នុងឆ្នាំ២០០៩នេះ។ ចំណែកឯករណីវិវាទចំនួន១៦%ផ្សេងៗទៀតត្រូវបានរាយការណ៍ថា បោះបង់ចោលបណ្តឹង និងមិនមានព័ត៌មានគ្រប់គ្រាន់អំពីដំណើរការនៃការដោះស្រាយសំរាប់ធ្វើការវិភាគបានឡើយ។ បើទោះបីជាលទ្ធផល នៃការវិភាគខាងលើ ឃើញថា បីភាគបួននៃដីវិវាទមិនទាន់ត្រូវបានដោះស្រាយក៏ដោយចុះ ប៉ុន្តែយើងក៏រកឃើញផងដែរថាចំនួនករណីនៃដីវិវាទជិតពាក់កណ្តាល គឺស្មើ៤៧%កំពុងត្រូវបានកាន់កាប់ និងប្រើប្រាស់ដោយភាគីដើមបណ្តឹង ហើយចំនួនករណីវិវាទដីធ្លីត្រឹមតែមួយភាគបួនប៉ុណ្ណោះដែល

កំពុងកាន់កាប់និងប្រើប្រាស់ដោយភាគីទាំងពីរ ឬកាន់កាប់ និងប្រើប្រាស់ដោយភាគីចុងចម្លើយ ( *សូមមើលតួលេខ ១.៣* ) ។

ចំពោះភាគីពាក់ពន្ធ័ក្នុងរឿងវិវាទដីធ្លី គឺភាគច្រើនមានជាប់ពាក់ពន្ធ័រវាងប្រជាពលរដ្ឋនៅតាមសហគមន៍ និងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ស្ថាប័នរបស់រាជរដ្ឋាភិបាល ឬមន្ត្រីយោយោធា។ យោងតាមរបាយការណ៍វិភាគបានអោយដឹងថាដើមបណ្តឹងជាកសិករមានជាង( ៣/៤) នៃសំណុំរឿងវិវាទទាំងអស់ដែលក្នុងនោះមានដើមបណ្តឹងជាសហគមន៍ជនជាតិដើមភាគតិចមានរហូតដល់៨.៥% ។ករណីវិវាទដីធ្លីជាច្រើនជាប់ទាក់ទៅនឹងភាពមិនច្បាស់លាស់នៃម្ចាស់កម្មសិទ្ធិលើអចលនៈទ្រព្យដែលភាគីវិវាទធ្វើការទាមទាររវាងសិទ្ធិលើកម្មសិទ្ធិដោយកំណត់លើលិខិតគតិយុត្តិ និងសិទ្ធិលើកម្មសិទ្ធិដោយកំណត់លើការកាន់កាប់ប្រើប្រាស់ជាក់ស្តែងជាលក្ខណៈប្រពៃណី។ ភាគីវិវាទដីធ្លីភាគច្រើនបានធ្វើការទាមទារជាម្ចាស់កម្មសិទ្ធិតាមមធ្យោបាយផ្សេងៗ ដូចជាតាមរយៈឯកសារផ្លូវការ ( អនុក្រឹត្យផ្តល់សម្បទានដីសេដ្ឋកិច្ច ) បណ្ណ័កម្មសិទ្ធិ (ចេញដោយគណៈកម្មការសុរិយោដី) ឬទាមទារសិទ្ធិកម្មសិទ្ធិ តាមរយៈសិទ្ធិភោគៈ និងប្រពៃណីទំនៀមទំលាប់ (ដូចជាមានចែងនៅក្នុងច្បាប់ភូមិបាល)។ តារាង ១.២ ខាងក្រោមនឹងបញ្ជាក់អំពីឯកសារណបនៃបណ្តឹង ទាមទារសិទ្ធិកម្មសិទ្ធិដោយភាគីវិវាទ។

*តលេខ ១.៣: សានភាពនៃការកាន់កាប់ដីទំនាស់*



**តារាង ១.២ ឯកសារណាបនៃបណ្ដឹងទាមទារសិទ្ធិកម្មសិទ្ធិលើដីវិវាទ**

| ឯកសារសំអាង (ដើមបណ្ដឹង) | ចំនួន | ភាគរយ នៃសុពលភាព |
|---|---|---|
| ប័ណ្ណកាន់កាប់ | ៥៤ | ៤៦.២ |
| ប័ណ្ណកម្មសិទ្ធិ | ៣២ | ២៧.៤ |
| សិទ្ធិកាន់កាប់ជាលក្ខណៈប្រពៃណី | ២០ | ១៧.១ |
| ផ្សេងៗ | ១១ | ៩.៤ |
| **សរុប** | **១១៧** | **១០០** |
| **ឯកសារសំអាង (ចុងចម្លើយ)** | **ចំនួន** | **ភាគរយ នៃសុពលភាព** |
| ឯកសារផ្ដល់សម្បទានដីសេដ្ឋកិច្ច | ១៦ | ២១.៦ |
| ឯកសារផ្ដល់សម្បទានដីសង្គមកិច្ច | ១ | ១.៤ |
| ប័ណ្ណកាន់កាប់ | ១៦ | ២១.៦ |
| ប័ណ្ណកម្មសិទ្ធិ | ២១ | ២៨.៤ |
| ផ្សេងៗ | ២០ | ២៧.០ |
| **សរុប** | **៧៤** | **១០០** |

## ដំណើរការនៃការដោះស្រាយវិវាទ

របាយការណ៍នៃការវិភាគបញ្ជាក់ថា ជិតពាក់កណ្ដាលនៃសំណុំរឿងវិវាទដីធ្លី គឺ(៤៩.២%)ក្នុងចំណោមសំណុំរឿងទាំងអស់២៣៦ករណី គឺភាគីវិវាទបានសំរេចជ្រើសរើសសមត្ថកិច្ចអាជ្ញាធរខេត្តធ្វើជាស្ថាប័នដាក់ពាក្យបណ្ដឹង និងសំរាប់ដោះស្រាយបណ្ដឹងរបស់ពួកគាត់។ ក្រៅពីនោះមានមួយភាគបួននៃវិវាទ គឺស្មើ ២៦% ភាគីវិវាទក៏បានដាក់បណ្ដឹងរបស់ពួកគាត់ទៅអាជ្ញាធរមូលដ្ឋាន និងគណៈកម្មការ

សុរិយោដី (មន្ត្រីរដ្ឋាភិបាលថ្នាក់ឃុំរហូតដល់ថ្នាក់ស្រុក)។ តួលេខវិភាគរបាយការណ៍ឆ្នាំ២០០៩នេះបញ្ជាក់ថា មិនមានភាពខុសប្លែកធំដុំឡើយ បើប្រៀបធៀបទៅនឹងរបាយការណ៍វិភាគឆ្នាំ២០០៨នោះ។ តួលេខ១.៤ខាងក្រោម នឹងផ្តល់ព័ត៌មានលំអិតអំពីចំនួនបណ្តឹងដែលបានដាក់ជូនទៅអាជ្ញាធរពាក់ព័ន្ធក្នុងចំណោមករណីវិវាទទាំង ២៣៦ករណី ។

***តួលេខ១.៤:អាជ្ញាធរពាក់ព័ន្ធដែលទទួលពាក្យបណ្តឹង***




## សូមបញ្ជាក់

ចំនួនពាក្យបណ្តឹងករណីវិវាទដីធ្លីដែលបានដាក់ជូនទៅអាជ្ញាធរពាក់ព័ន្ធនោះ គឺមានលើសពី២៣៦ករណី ព្រោះថាមានករណីវិវាទខ្លះ ដើមបណ្តឹងបានដាក់ពាក្យបណ្តឹងទៅស្ថាប័នអាជ្ញាធរច្រើនកន្លែង។

*តួលេខ ១.៥: ស្ថានភាពនៃការដោះស្រាយវិវាទ*




លទ្ធផលនៃការធ្វើអន្តរាគមន៍ដែលបានដាក់ពាក្យបណ្ដឹងជូនទៅអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗជាច្រើននោះឃើញថាចំនួនករណីវិវាទជិត ៧០%មិនទាន់ត្រូវបានដោះស្រាយនៅឡើយទេ ហើយករណីវិវាទមួយចំនួនទៀតបានដំណើរការខ្លះ និង ខ្លះទៀតមិនមានព័តិមានអំពីស្ថានភាពនៃដំណោះស្រាយទេ។ តួលេខ១.៥នេះបង្ហាញថា ករណីវិវាទដីធ្លីមានត្រឹមតែ១៧.៤%ប៉ុណ្ណោះ ឬស្មើ៤១ករណីដែលត្រូវបានដោះស្រាយ។ ក្នុងចំណោមករណីវិវាទដីធ្លីដែលបានដោះស្រាយទាំង៤១ករណីនោះគឺមាន ៤១.៥%ត្រូវបានដោះស្រាយដោយអាជ្ញាធរមូលដ្ឋាន និង២២% ត្រូវបានដោះស្រាយដោយប្រព័ន្ធតុលាការ។ ទោះជាយ៉ាងណាក៏ដោយភាគច្រើននៃករណីវិវាទដីធ្លី ដែលត្រូវបានដោះស្រាយដោយអាជ្ញាធរមូលដ្ឋាននោះគឺដោះស្រាយបានតែផ្នែកខ្លះៗ នៃដីទំនាស់ប៉ុណ្ណោះ ហើយចំពោះករណីវិវាទដីធ្លីដែលត្រូវបានដោះស្រាយដោយតុលាការនោះភាគច្រើន គឺសំរេចអោយទៅភាគីចុងចម្លើយ ( *សូមមើលតារាង ១.៣ ខាងក្រោម* )។

### តារាង១.៣: ស្ថានភាពដំណោះស្រាយករណីវិវាទដីធ្លី ឆ្នាំ ២០០៩

| ស្ថានភាពដោះស្រាយ | អាជ្ញាធរដោះស្រាយ | | | | | | |
|---|---|---|---|---|---|---|---|
| | តុលាការ | សុរិយោដី | អាជ្ញាធរមូលដ្ឋាន | អាជ្ញាធរជាតិ | អាជ្ញាធរពាក់ព័ន្ធ | គ្មានទិន្នន័យ | សរុប |
| បានទៅភាគីដើមបណ្តឹង | ១ | ០ | ២ | ០ | ៣ | ០ | ៦ |
| បានទៅភាគីចុងចម្លើយ | ៤ | ០ | ០ | ១ | ០ | ០ | ៥ |
| បានទៅភាគីទាំងពីរ | ១ | ២ | ៤ | ០ | ១ | ១ | ៩ |
| បានផ្នែកខ្លះៗ | ៣ | ០ | ១១ | ១ | ១ | ៥ | ២១ |
| **សរុប** | **៩** | **២** | **១៧** | **២** | **៥** | **៦** | **៤១** |
| ***ភាគរយ*** | ***២២.០*** | ***៤.៩*** | ***៤១.៥*** | ***៤.៩*** | ***១២.២*** | ***១៤.៦*** | ***១០០*** |

ក្នុងចំណោមករណីទាំង៤១ដែលមានចំណាត់ការដោះស្រាយនោះ គឺមានករណីជិតពាក់កណ្តាលត្រូវបានដោះស្រាយរួចហើយករណីផ្សេងទៀត គឺដោះស្រាយបានត្រឹមតែផ្នែកខ្លះៗប៉ុណ្ណោះ។ តារាង១.៤ខាងក្រោមនឹងបញ្ជាក់អំពីសេចក្តីសំរេចរបស់អាជ្ញាធរពាក់ព័ន្ធ។

### តារាង ១.៤ : លទ្ធផលយកដំណើរការដោះស្រាយ

| **ករណីដែលបានដោះស្រាយ** | **ចំនួនករណី** | **ភាគរយ** |
|---|---|---|
| បានទៅដើមបណ្តឹង | ៦ | ១៤.៦ |
| បានទៅចុងចម្លើយ | ៥ | ១២.២ |
| បានទៅភាគីទាំងពីរ | ៩ | ២២.០ |
| ដោះស្រាយបានផ្នែកខ្លះៗ | ២១ | ៥១.២ |
| **សរុប** | **៤១** | **១០០** |

នៅក្នុងអំឡុងពេលកំពុងដំណើរការដោះស្រាយរឿងក្តី មានបញ្ហាជាច្រើនបានកើតឡើងដែលជាឧបសគ្គក្នុងការដោះស្រាយ ហើយករណីវិវាទមួយចំនួនអាចឈានទៅដល់មានអំពើហិង្សាការគំរាមកំហែង និងរហូតដល់ករណីខ្លះមានការចាប់ខ្លួន និងឃុំខ្លួនទៀតផង។ យោងតាមការវិភាគទិន្នន័យនេះ ក្នុងចំណោមករណីវិវាទចំនួន២៣៦ ករណីនោះ មានអំពើហិង្សា និងការគំរាមកំហែង៤៥% និងប្រមាណ១៨ %ផ្សេងទៀតឈានដល់ការចាប់ខ្លួន និងឃុំខ្លួនក្នុងពន្ធនាគារ ។

## *សេចក្តីសន្និដ្ឋាន*

យោងតាមរបាយការណ៏នៃការវិភាគទិន្នន័យករណីវិវាទដីធ្លីឆ្នាំ២០០៩ យើងអាចធ្វើសេចក្តីសន្និដ្ឋានបានថាករណីវិវាទដីធ្លីនៅក្នុងឆ្នាំ២០០៩មានការថយចុះ បើប្រៀបធៀបទៅនឹងរបាយការណ៏វិភាគទិន្នន័យឆ្នាំ២០០៨។ បើទោះជាយ៉ាងនេះក្តី ខេត្តចំនួន៣ គឺខេត្តបាត់ដំបង ខេត្តព្រះសីហនុ និងខេត្តកណ្តាល នៅតែមានតួលេខខ្ពស់ជាងគេដែលទិន្នន័យនេះដូចគ្នាទៅនឹងរបាយការណ៏នៃការវិភាគទិន្នន័យឆ្នាំ២០០៨។ ករណីវិវាទដីធ្លីជាងពាក់កណ្តាលបានកើតឡើងលើប្រភេទដីកសិកម្ម ហើយក្នុងនោះមានចំនួនករណីវិវាទត្រឹមតែ១៧%ប៉ុណ្ណោះ ដែលមានដំណើរការក្នុងការដោះស្រាយ។ ភាគច្រើននៃករណីវិវាទគឺកើតឡើងរវាងសហគមន៏ជាមួយនឹងភាគីវិវាទម្ខាងទៀត ដូចជាភាគីតំណាងក្រុមហ៊ុន ស្ថាប័នរដ្ឋាភិបាល និងមន្ត្រីយោធា។ បើទោះបីជាមួយភាគប្រាំនៃករណីវិវាទត្រូវបានដោះស្រាយ ប៉ុន្តែមានត្រឹមតែជិតពាក់កណ្តាលប៉ុណ្ណោះដែលបានដោះស្រាយចប់សព្វគ្រប់ ហើយនៅជាងពាក់កណ្តាលទៀតដោះស្រាយបានតែផ្នែកខ្លះ។នៃដីវិវាទប៉ុណ្ណោះ។ លទ្ធផលនៃការវិភាគក៏បាន

អោយដឹងថា  អាជ្ញាធរមូលដ្ឋានដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការនៃការដោះស្រាយ វិវាទដីធ្លី ព្រោះជាស្ថាប័នរដ្ឋាភិបាលដែលទទួលពាក្យបណ្តឹងមុនគេនៅពេលដែលមាន ទំនាស់កើតឡើង។

# ទិន្នន័យករណីវិវាទដីធ្លីបញ្ជាក់តាមផែនទីភូមិសាស្ត្រ

## ឧបសម្ព័ន្ធ ១: ចំនួនករណីវិវាទដីធ្លីនៅតាមបណ្តាខេត្តនីមួយៗ

ចំនួនគ្រួសារដែលរងផលប៉ះពាល់តាមបណ្តាលខេត្តនីមួយៗ







Data sources:
Number of land Dispute Cases: NGO Forum
Water body: JICA dataset 2002
Provincial boundary,
International boundary: Department of Geography 2005

# ឧបសម្ព័ន្ធ ២: ផែនទីបញ្ជាក់អំពីចំនួនគ្រួសាររងផលប៉ះពាល់

ចំនួនគ្រួសាររងផលប៉ះពាល់តាមបណ្តាលខេត្តនីមួយៗ







Data sources:
Number of Affected Households: NGO Forum
Water body: JICA dataset 2002
Provincial boundary,
International boundary: Department of Geography 2005